# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ បុណ្យនៃសេចក្តីស្រឡាញ់

website ៖ www.hoksavann.org

ថ្ងៃទី៣១ មីនា ២០០៩



បុណ្យនៃសេចក្តីស្រឡាញ់នេះ កើតឡើងនៅប្រទេសអឺរ៉ុប ពុំមែនជាវប្បធម៌របស់ខ្មែរឡើយ តើហេតុអ្វីបានជាក្នុងប្រតិទិនខ្មែរមានចុះបុណ្យនេះជាកាលបរិច្ឆេទប្រចាំឆ្នាំ ដែលពុំមែនជាប្រពៃណីរបស់ខ្មែរ រហូតដល់ដាក់ឃ្លាតចាកន័យដើមរបស់គេថា ទិវាបុណ្យសង្សារថ្ងៃ១៤កុម្ភៈថែមទៀត ។ ក្រសួងវប្បធម៌ខ្មែរ ដែលជាក្រសួងបង្កើតឡើងសំរាប់រក្សាការពារវប្បធម៌ខ្មែរ មិនបានយកចិត្តទុកដាក់មើលការខុសត្រូវឲ្យបានសព្វគ្រប់ បណ្តោយឲ្យវប្បធម៌របៀបនេះចូលមកប្រទេសកម្ពុជា ព្រមទាំងបានទទួលស្គាល់ចុះក្នុងប្រតិទិនរបស់ជាតិទៀតផង ដែលធ្វើឲ្យយុវជននិងយុវនារីខ្មែរខ្លះ ដែលខ្វះការពិចារណាទទួលយកហើយអនុវត្តអបាយមុខល្បែងស្រីខុសពីន័យដើមរបស់គេថែមទៀត ។ គួរតែក្រសួងវប្បធម៌ប្រាប់អ្នកសរសេរប្រតិទិន កុំឲ្យដាក់ទិវានេះនៅក្នុងប្រតិទិនក្នុងឆ្នាំតៗមកទៀត ។

តាមការស្រាវជ្រាវ បុណ្យហេតុដែលនាំឲ្យកើតទិវានេះ មានឯកសារនិយាយខុសគ្នា ពុំមែនជារឿងពិតតាមប្រវត្តិសាស្ត្រទេ ជារឿងព្រេងនិទាន ។ មានឯកសារខ្លះថា រឿងនេះមានទំនាក់ទំនងទៅសាសនាគ្រីស្ត ។ ដំណើររឿងគឺ មានបុរសម្នាក់ឈ្មោះសាំង-វ៉ាឡង់ថែន (Saint Valentine) ជាព្រះសង្ឃកាតូលិករ៉ូម៉ាំង នៅក្រុងរ៉ូម ប្រទេសអ៊ីតាលី ត្រូវកាត់ទោសប្រហារជីវិត ដោយកំហុសប្រឆាំងនឹងអធិរាជក្លូឌីយូស (Claudius) ។ អធិរាជនេះបានដាក់បញ្ជាមិនឲ្យ

បុរសរៀបការជាមួយនឹងស្ត្រីណាទាំងអស់ ដើម្បីទុកបុរសឲ្យមានភាពបរិសុទ្ធសំរាប់យកទៅធ្វើទាហាន ។ ព្រះសង្ឃកាតូលិកដូចឈ្មោះខាងលើបានប្រឆាំងនឹងបទបញ្ជារបស់អធិរាជនេះ ដោយលួចរៀបការជាសម្ងាត់ ក៏ត្រូវកាត់ទោសប្រហារជីវិតនៅថ្ងៃ១៤កុម្ភៈឆ្នាំ២៦៩នៃគ.ស. គឺជាថ្ងៃនៃទិវានៃសេចក្ដីស្រឡាញ់នេះឯង ។ ឯកសារបានឲ្យហេតុផលខុសគ្នាថា ទិវានេះធ្វើដើម្បីរំលឹកដល់ខួបនៃការស្លាប់របស់ព្រះសង្ឃកាតូលិកនេះ, ធ្វើដើម្បីធ្វើខ្លួនឲ្យទៅជាអ្នកគ្រីស្ដសាសនិកពិតប្រាកដ, ធ្វើដើម្បីរក្សាប្រពៃណីក្រុងរ៉ូមបុរាណថា នៅពាក់កណ្ដាលខែកុម្ភៈ ជាពេលចាប់ផ្ដើមរដូវត្រជាក់ ។ មួយទៀត ធ្វើពិធីនេះដើម្បីនឹកដល់អាទិទេពឈ្មោះហ្វូនុស (faunus) ដែលជាអទិទេពកសិកម្ម ។

លើកយកឯកសារខ្លះមកបញ្ជាក់អំពីបុព្វហេតុដែលនាំឲ្យគេធ្វើទិវានេះ គ្មានឃើញមូលដ្ឋានពិតប្រាកដទេ ហើយគេធ្វើទិវានេះដើម្បីប្រយោជន៍អ្វីដែរ ។ ទិវានេះគ្រាន់តែជាទំនៀមទម្លាប់របស់ពួកអឺរ៉ុប ពុំមែនជារបស់ខ្មែរទេ ហើយធ្វើដោយផ្អែកទៅលើរឿងព្រេងរបស់ខ្លួន ពុំមែនជារឿងទាក់ទងជាប្រវត្តិសាស្ត្រសោះឡើយ ព្រោះឈ្មោះសាំង-វ៉ាឡង់ថែននេះ គ្មានឃើញប្រវត្តិពិតក្នុងប្រវត្តិសាស្ត្រពួកអឺរ៉ុបឡើយ ។

តាមការសង្កេត រាល់ថ្ងៃ១៤កុម្ភៈ ដែលជាទិវានៃសេចក្ដីស្រឡាញ់នេះ ប្រទេសអង់គ្លេស សហរដ្ឋអាមេរិក បារាំង កាណាដា គ្មានឃើញធ្វើពិធីនេះជាធំដុំទេ ឃើញមានខ្លះដោយជូនវត្ថុជាអនុស្សាវរីយ៍ និងសរសេរសំបុត្រជូនពរដល់អ្នកជាទីគោរពនិងជាទីរាប់អាន ដូចម្ដាយឪពុក បងប្អូន និងមិត្តភក្ដិ បើមានជូនគូសង្សារក៏មានតិចណាស់ ហើយគេមិនយកទិវានេះជាថ្ងៃរួមភេទ ដូចជាយុវជននិងយុវនារីខ្មែរខ្លះនោះឡើយ ។ ទិវានេះមិនត្រូវបានយកមកអនុវត្តជាទូទៅក្នុងចំណោមអ្នកកាន់សាសនាគ្រីស្ដឡើយ ដោយមានគ្រីស្ដសាសនិកជននិកាយខ្លះមិនពេញចិត្តយកមកអនុវត្តដែរ ។

ព្រះពុទ្ធសាសនាបានប្រៀនប្រដៅយើងថា មុននឹងជឿអ្វីមួយមកអនុវត្តត្រូវពិចារណាឲ្យបានល្អិតល្អន់ ព្រោះអនុវត្តតាមជំនឿខ្លះ នាំឲ្យខូចប្រយោជន៍ខ្លួននិងប្រយោជន៍សង្គម ។ យ៉ាងណាមិញ ទិវានៃសេចក្ដីស្រឡាញ់ ដែលខ្មែរខ្លះយកមកក្រឡៃឲ្យលើសពីគេ ឲ្យខូចពីទិវារបស់គេថាបុណ្យសង្សារ គឺជាទិវានៃ

ការប្រព្រឹត្តអំពើអបាយមុខ នាំឲ្យខូចប្រយោជន៍សង្គមធ្ងន់ណាស់ ។ ខូចប្រយោជន៍ គឺពេលទិវានេះមកដល់ យុវជននិងយុវនារីខ្មែរខ្លះជ្រួលជ្រើមដូចមមាចចូលភ្លើងដើរកាត់ជួបគ្នា មានខ្លះហ៊ានប្រព្រឹត្តអំពើកាមគុណថែមទៀត កន្លងប្រពៃណីរបស់ជាតិខ្លួន គេចមិនព្រមទៅសាលារៀន ដែលជាវ័យសំអាតខ្លួនដើម្បីសិក្សាយកចំណេះ កសាងខ្លួន កសាងគ្រួសារ កសាងសង្គមរបស់ខ្លួន ។ អបាយមុខ ល្បែងស្រី ល្បែងស្រា ល្បែងស៊ីសង ពិតជាធ្វើឲ្យអ្នកប្រព្រឹត្តវិនាសប្រាកដណាស់ គឺខូចការសិក្សា អស់ទ្រព្យសម្បត្តិ ខូចការងារ ខូចសុខភាព កើតចោរលួច ចោរប្លន់ កើតអំពើហឹង្សាគ្រប់យ៉ាង ។ កុំប្រើពាក្យថាបុណ្យ ព្រោះពាក្យបុណ្យជាការស្ងប់ផ្លូវចិត្ត ពុំមានរាគៈ ទោសៈ មោហៈ បើប្រព្រឹត្តអបាយមុខ ឈ្មោះថាទិវាប្រព្រឹត្តធ្វើអំពើបាបទៅវិញ ។

ដើម្បីឲ្យទៅជាយុវជននិងយុវនារីល្អ ត្រូវផ្អែកលើកត្តាពីរយ៉ាង គឺវិជ្ជាសម្បត្តិ និងចរិយាសម្បត្តិ គឺត្រូវសិក្សាឲ្យបានជ្រៅជ្រះ និងការប្រព្រឹត្តឲ្យបានល្អត្រឹមត្រូវ មិនដើរលេងពាលាអាវ៉ាសែ ប្រព្រឹត្តអបាយមុខផ្សេងៗ ស្គាល់បាបស្គាល់បុណ្យ ស្គាល់គុណស្គាល់ទោសជាដើម ។ ទិវានៃសេចក្តីស្រឡាញ់ដែលក្លាយមកជាទិវាបុណ្យស្នេហានេះ ត្រូវកុំឲ្យកើតមានក្នុងសង្គមកម្ពុជា ព្រោះជាពិសពុលរបស់សង្គមខ្មែរ ។ កុំដាក់ទិវានេះក្នុងប្រតិទិនប្រចាំឆ្នាំ ។ ក្រសួងវប្បធម៌គប្បីយកចិត្តទុកដាក់ឲ្យខ្លាំងចំពោះវប្បធម៌បរទេសហូរចូលមកប្រទេសកម្ពុជា ។៚

❄ ❄

❄